# សេចក្តីណែនាំខ្លីៗលើការចុះឈ្មោះ និងការបោះឆ្នោតក្នុងរដ្ឋវិចតូរីយ៉ា

លំនាំដែលរដ្ឋវិចតូរីយ៉ាត្រូវបានគ្រប់គ្រង ប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់យើង។ លោកអ្នកអាចជួយធ្វើឲ្យមានរូបរាងដល់រដ្ឋវិចតូរីយ៉ា ដោយសារការចុះឈ្មោះ និងការបោះឆ្នោត។

## ការចុះឈ្មោះបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោតគឺជាការសំខាន់ ដ្បិតអីវាអនុញ្ញាតឲ្យលោកអ្នកបញ្ចេញមតិលើនរណាដែលនឹងធ្វើជាតំណាងលោកអ្នកនៅថ្នាក់រដ្ឋាភិបាលសហព័ន្ធ រដ្ឋ និងសាលាក្រុង។ ថ្នាក់រដ្ឋាភិបាលនីមួយៗមានករណីយកិច្ចដែលអាចប៉ះពាល់ដល់លោកអ្នក និងសហគមន៍របស់លោកអ្នក។

ដើម្បីបោះឆ្នោះសហព័ន្ធ រដ្ឋ និងសាលាក្រុង លោកអ្នកត្រូវតែចុះឈ្មោះបោះឆ្នោតឲ្យបានត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោត។ បញ្ជីបោះឆ្នោតគឺជាបញ្ជីឈ្មោះ និងអាសយដ្ឋាននៃអ្នកបោះឆ្នោត។

### តើខ្ញុំត្រូវចុះឈ្មោះដោយរបៀបណា?

ការចុះឈ្មោះគឺជាការងាយស្រួល ហើយលោកអ្នកត្រូវការចុះឈ្មោះតែ១ដងប៉ុណ្ណោះដើម្បីបោះឆ្នោតសហព័ន្ធ រដ្ឋ និងសាលាក្រុង។

អ្វីដែលលោកអ្នកត្រូវធ្វើនោះគឺគ្រាន់តែបំពេញ ហើយផ្ញើហ្វ៍មចុះឈ្មោះដែលអាចទទួលយកបានពីគេហទំព័ររបស់ VEC ប៉ុណ្ណោះ។

លោកអ្នកអាចទទួលយកហ្វ៍មបានផងដែរនៅតាមប៉ុស្តិ៍សំបុត្រណាមួយ ឬផ្សារធំ Coles ឬ Bi-Lo ឬពីការិយាល័យ VEC។ លោកអ្នកអាចស្នើសុំឲ្យគេផ្ញើហ្វ៍មមួយច្បាប់មកលោកផងដែរ ដោយទូរស័ព្ទមកយើងលេខ 13 18 32  ឬ 9209 0112 ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា។

### តើខ្ញុំត្រូវតែចុះឈ្មោះឬ?

ប្រាកដណាស់។ វាជាការចាំបាច់ដែលត្រូវចុះឈ្មោះ ប្រសិនបើលោកអ្នក:

- ជាពលរដ្ឋអូស្ត្រាលី;
- មានអាយុ១៨ឆ្នាំ ឬលើសពីនេះ; ហើយ
- បានរស់នៅតាមអាសយដ្ឋានបច្ចុប្បន្នរបស់លោកអ្នកក្នុងរដ្ឋវិចតូរីយ៉ា អស់រយៈពេលយ៉ាងតិចណាស់មួយខែ។

## ការចុះឈ្មោះពិសេស

ហ្វ៊មចុះឈ្មោះពិសេស សំរាប់កាលៈទេសៈខាងក្រោមនេះ គឺអាចទទួលយកបាននៅលើតាមគេហទំព័ររបស់ VEC ឬដោយទូរស័ព្ទទៅ VEC លេខ 13 18 32 ឬ 9209 0112 ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា។

### ចុះប្រសិនបើខ្ញុំពុំអាចធ្វើដំណើរទៅកាន់ទីកន្លែងបោះឆ្នោត?

លោកអ្នកអាចចុះឈ្មោះជាអ្នកបោះឆ្នោតទូទៅតាមប៉ុស្តិ៍ ប្រសិនបើលោកអ្នកមានការលំបាកនឹងធ្វើដំណើរទៅមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ លោកអ្នកអាចដាក់ពាក្យសុំជាអ្នកបោះឆ្នោតទូទៅតាមប៉ុស្តិ៍ ប្រសិនបើលោកអ្នកៈ

- រស់នៅឆ្ងាយជាង២០គីឡូម៉ែត្រពីមណ្ឌលបោះឆ្នោត;
- មានជម្ងឺ ឬមើលថែសុខភាពនរណាម្នាក់ដែលឈឺ*;
- កាន់ជំនឿសាសនាដែលហាមឃាត់លោកអ្នកពីការបោះឆ្នោតនៅចំថ្ងៃបោះឆ្នោត;
- កំពុងតែជាប់ពន្ធនាគារតិចជាង៥ឆ្នាំ*; ឬ
- ជាអ្នកជម្ងឺនៅតាមផ្ទះមើលថែមនុស្សចាស់;
- បានចុះឈ្មោះជាអ្នកបោះឆ្នោតសម្ងាត់; ឬ
- មានអាយុ៧០ឆ្នាំ ឬចាស់ជាងនេះ*;

*សំរាប់ការបោះឆ្នោតប្រចាំរដ្ឋ និងសាលាក្រុងប៉ុណ្ណោះ

ប្រសិនបើលោកអ្នកចុះឈ្មោះជាអ្នកបោះឆ្នោតទូទៅតាមប៉ុស្តិ៍ នុះគេនឹងផ្ញើសម្ភារៈបោះឆ្នោតទៅលោកអ្នកបន្ទាប់ពីការជ្រើសរើសបេក្ខជនបានបិទសំរាប់ការបោះឆ្នោត។

### ចុះប្រសិនបើខ្ញុំកំពុងរស់នៅ ឬធ្វើដំណើរនៅបរទេស?

លោកអ្នកប្រហែលជាអាចចុះឈ្មោះថាជាអ្នកបោះឆ្នោតពីបរទេស ប្រសិនបើលោកអ្នកៈ

- បានចុះឈ្មោះ ហើយមានបំណងនឹងចាកចេញពីប្រទេសអូស្ត្រាលី នៅក្នុងរយៈពេល៣បីខាងមុខ ហើយមានបំណងនឹងវិលត្រឡប់មកកាន់ប្រទេសអូស្ត្រាលីវិញក្នុងរយៈពេល៦ឆ្នាំ;
- បានចុះឈ្មោះ ហើយចាកចេញពីប្រទេសអូស្ត្រាលីតិចជាង៣ឆ្នាំកន្លងទៅ ហើយមានបំណងនឹងវិលត្រឡប់មកកាន់ប្រទេសអូស្ត្រាលីវិញក្នុងរយៈពេល៦ឆ្នាំ បន្ទាប់ពីបានចាកចេញ; ឬ
- កំពុងរស់នៅឯបរទេស ហើយមិនទាន់បានចុះឈ្មោះ។

ការចុះឈ្មោះជាអ្នកបោះឆ្នោតពីបរទេស មានន័យថាលោកអ្នកនឹងត្រូវបោះឆ្នោតដោយផ្ទាល់នៅមុខតំណែងខាងការទូតអូស្ត្រាលី (Australian Diplomatic Post ) ដែលផ្តល់កិច្ចបំរើខាងកុងស៊ុលពេញ

លេញ ឬដោយដាក់ពាក្យសុំការបោះឆ្នោតតាមប៉ុស្តិ៍។

### ចុះប្រសិនបើខ្ញុំមិនចង់ឲ្យអាសយដ្ឋានរបស់ខ្ញុំបង្ហាញឃើញនៅក្នុងបញ្ជីចុះឈ្មោះបោះឆ្នោត ដោយសារមូលហេតុសុវត្ថិភាព?

លោកអ្នកអាចដាក់ពាក្យសុំចុះឈ្មោះថាជាអ្នកបោះឆ្នោតដោយសម្ងាត់ ប្រសិនបើលោកអ្នកជឿថាដោយសារការមានអាសយដ្ឋានរបស់លោកអ្នកបោះពុម្ពនៅពីលើបញ្ជីចុះឈ្មោះបោះឆ្នោត នុះសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោកអ្នក ឬសុវត្ថិភាពគ្រួសាររបស់លោកអ្នកនឹងស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។ ការបោះឆ្នោតជាសម្ងាត់មានន័យថា អាសយដ្ឋានរបស់លោកអ្នកនឹងមិនបង្ហាញឲ្យឃើញនៅក្នុងការបោះពុម្ពបញ្ជីបោះឆ្នោតតទៅអនាគតឡើយ។

### ចុះប្រសិនបើខ្ញុំពុំមានទីលំនៅ ឬពុំមានអាសយដ្ឋានទៀងទាត់?

លោកអ្នកអាចដាក់ពាក្យសុំចុះឈ្មោះថាជាអ្នកបោះឆ្នោតដោយពុំមានអាសយដ្ឋានទៀងទាត់ ប្រសិនបើលោកអ្នកពុំមានអាសយដ្ឋានទៀតទាត់ទេ។

## ការចុះឈ្មោះបោះឆ្នោតសាលាក្រុង

### តើខ្ញុំបានចុះឈ្មោះបោះឆ្នោតហើយឬនៅ?

លោកអ្នកនឹងត្រូវបានចុះឈ្មោះជាស្វ័យប្រវត្តិសំរាប់ការបោះឆ្នោតសាលាក្រុង ប្រសិនបើ:

- លោកអ្នកមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតប្រចាំរដ្ឋ និងសហព័ន្ធសំរាប់អាសយដ្ឋានបច្ចុប្បន្នរបស់លោកអ្នក; ឬ
- លោកអ្នកមានផ្ទះដីធ្លីនៅក្នុងសាលាសង្កាត់ដែលការបោះឆ្នោតកំពុងប្រព្រឹត្តទៅ តែមិនបានរស់នៅតាមផ្ទះដីធ្លីនោះ ហើយលោកអ្នកជាបុគ្គលទីមួយ ឬទីពីរដែលមានឈ្មោះចុះនៅលើឯកសារពន្ធផ្ទះដីធ្លីរបស់សាលាក្រុងនោះ; ឬ
- លោកអ្នកបានដាក់ពាក្យសុំទៅសាលាក្រុង ដើម្បីចុះឈ្មោះបោះឆ្នោតសំរាប់សាលាក្រុងនោះ (សូមមើលខាងក្រោមនេះ)។

**លោកអ្នកក៏អាចដាក់ពាក្យសុំចុះឈ្មោះបានដែរ ប្រសិនបើលោកអ្នកមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ ហើយ:**

- លោកអ្នកមិនមែនជាពលរដ្ឋអូស្ត្រាលីដែលរស់នៅ ហើយបង់ពន្ធផ្ទះដីធ្លីនៅក្នុងសង្កាត់ ដែលការបោះឆ្នោតកំពុងប្រព្រឹត្តទៅ; ឬ
- លោកអ្នកបង់ពន្ធផ្ទះដីធ្លីសំរាប់ផ្ទះដែលលោកអ្នករស់នៅ ហើយពុំមានសិទ្ធិបោះឆ្នោតឯទៀតនៅក្នុងសង្កាត់ដែលការបោះឆ្នោតកំពុងប្រព្រឹត្តទៅ ឧទាហរណ៍ លោកអ្នកជាជួលហាងលក់ ហើយមានឈ្មោះចុះនៅលើឯកសារពន្ធផ្ទះដីធ្លី ដើម្បីទទួលលិខិតពន្ធផ្ទះដីធ្លី ឬមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីម្ចាស់ផ្ទះដីធ្លីឲ្យបោះឆ្នោតជំនួសគេ; ឬ

- លោកអ្នកជានាយក ឬលេខាធិការក្រុមហ៊ុននៃសាជីវកម្មដែលបង់ពន្ធផ្ទះដីធ្លីនៅក្នុងសង្កាត់ដែលការបោះឆ្នោតកំពុងប្រព្រឹត្តទៅ ហើយពុំមានសិទ្ធិបោះឆ្នោតណាទៀតនៅក្នុងសង្កាត់នោះ។

សូមទាក់ទងជាមួយសាលាក្រុងរបស់លោកអ្នក ប្រសិនបើជំពូកពិសេសខាងលើណាមួយនៃការមានសិទ្ធិអនុវត្តចំពោះលោកអ្នក។

## តើនរណាមានសិទ្ធិទទួលយកព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត?

VEC បានបង្កើតគោលការណ៍ភាពជាឯកជន *(Privacy Policy)* មួយដើម្បីការពារព័ត៌នៃការចុះឈ្មោះ និងភាពជាឯកជននៃអ្នកបោះឆ្នោត។

ច្បាប់នៃការបោះឆ្នោត ឆ្នាំ២០០២ (រដ្ឋវិចតូរីយ៉ា) (Electoral Act 2002) (Victoria) តម្រូវឲ្យ VEC ផ្តល់ព័ត៌នូវមានជាក់លាក់ទៅឲ្យអ្នកយកចិត្តទុកដាក់ខ្លះដូចជាគណៈបក្សនយោបាយ សមាជិករដ្ឋសភា និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

ច្បាប់នៃការបោះឆ្នោតក៏អនុញ្ញាតឲ្យ VEC ផ្តល់នូវព័ត៌មានជាក់លាក់ខ្លះទៅឲ្យបុគ្គលម្នាក់ៗ និងអង្គការនានាផងដែរ។ ការនេះអាចកើតមានឡើងប្រសិនបើនៅក្នុងកាលៈទេសៈបង្ហាញឲ្យឃើញថាផលប្រយោជន៍សាធារណៈក្នុងការផ្តល់នូវព័ត៌មានដែលបានស្នើសុំនោះ មានទម្ងន់ជាងផលប្រយោជន៍សាធារណៈក្នុងការការពារភាពឯកជននៃព័ត៌មានផ្ទាល់ខ្លួន។

បុគ្គលម្នាក់ៗ និងអង្គការនានាដែលបានផ្តល់ឲ្យនូវព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត ត្រូវបានចុះនៅលើបញ្ជីគេហទំព័ររបស់ VEC។ អ្នកបោះឆ្នោតទាំងឡាយណាដែលមិនចង់ឲ្យព័ត៌មានរបស់ខ្លួនបង្ហាញនៅលើបញ្ជីបោះឆ្នោតដោយព្រោះមូលហេតុសុវត្ថិភាព អាចដាក់ពាក្យសុំទៅអ្នកកាន់កាប់បញ្ជីចុះឈ្មោះថាជាអ្នកបោះឆ្នោតសម្ងាត់។

## បោះឆ្នោតនៅក្នុងការបោះឆ្នោត

ប្រសិនបើលោកអ្នកបានចុះឈ្មោះបោះឆ្នោត នុះលោកអ្នកត្រូវតែបោះឆ្នោតនៅគ្រប់ទាំងការបោះឆ្នោតប្រចាំសហព័ន្ធ រដ្ឋ និងសាលាក្រុង។ ប្រសិនបើលោកអ្នកមិនបានបោះឆ្នោតដោយគ្មានមូលហេតុគ្រប់គ្រាន់ទេ លោកអ្នកអាចត្រូវគេផាកពិន័យ។ មានតែអ្នកបោះឆ្នោតដែលពុំមានទីលំនៅអចិន្ត្រៃយ៍ ឬអ្នកបោះឆ្នោតដែលមានអាយុ៧០ឆ្នាំឡើងទៅ ត្រូវបានលើកលែងពីការបោះឆ្នោតសាលាក្រុង។

### ការបោះឆ្នោតសហព័ន្ធ

ការបោះឆ្នោតសហព័ន្ធតែងធ្វើឡើងនៅថ្ងៃសៅរ៍ ហើយត្រូវបានចាត់ចែងឡើងដោយឯករាជពីគណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី (AEC)។ ការបោះឆ្នោតសហព័ន្ធអាចធ្វើឡើងនៅពេលណាមួយក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីការបោះឆ្នោតណាមួយ។

សភាសហព័ន្ធអូស្ត្រាលីបង្កើតឡើងដោយសភាពីរ - សភាដំណាងរាស្ត្រ (ឬហៅថាសភាជាន់ទាប) និងព្រឹទ្ធសភា (ឬសភាជាន់ខ្ពស់)។

### តើខ្ញុំបោះឆ្នោតជ្រើសរើសនរណា?

លោកអ្នកបោះឆ្នោតសហព័ន្ធ ដើម្បីជ្រើសរើសបេក្ខជនឲ្យធ្វើជាតំណាងលោកអ្នកនៅក្នុងសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។

ប្រទេសអូស្ត្រាលីត្រូវបានបែងចែកជាមណ្ឌលបោះឆ្នោតសភាតំណាងរាស្ត្រចំនួន១៥០។ នៅក្នុងចំនួនទាំងនេះ អ្នកបោះឆ្នោតវិចតូរីយ៉ាជ្រើសរើសអ្នកតំណាងរាស្ត្រចំនួន៣៧នាក់ ឲ្យធ្វើការសំរាប់អាណត្តិរហូតដល់ទៅ៣ឆ្នាំ។

នៅរៀងរាល់ការបោះឆ្នោតសហព័ន្ធនីមួយៗ អ្នកបោះឆ្នោតវិចតូរីយ៉ាក៏ជ្រើសរើសព្រឹទ្ធសភាវិចតូរីយ៉ាចំនួន៦នាក់ ក្នុងចំណោមព្រឹទ្ធសភាវិចតូរីយ៉ា១២នាក់ផងដែរ ឲ្យធ្វើការសំរាប់អាណត្តិ៦ឆ្នាំ។

## ការបោះឆ្នោតប្រចាំរដ្ឋ

ការបោះឆ្នោតប្រចាំរដ្ឋត្រូវប្រព្រឹត្តទៅរវាង៤ឆ្នាំម្តង នៅថ្ងៃអាទិត្យចុងក្រោយនាខែវិច្ឆិកា ហើយត្រូវបានចាត់ចែងឡើយដោយឯករាជពី VEC។ នឹងមានការបោះឆ្នោតប្រចាំរដ្ឋនៅក្នុងឆ្នាំ២០០៦ និងឆ្នាំ២០១០។

សភានៃរដ្ឋវិចតូរីយ៉ាត្រូវចែកចេញជាតំបន់៨៨សភានីតិបញ្ញត្តិ (សភាជាន់ទាប) ហើយចាប់ពីការបោះឆ្នោតប្រចាំរដ្ឋឆ្នាំ២០០៦ទៅ ចែកចេញជាភូមិភាគ៨ប្រឹក្សានីតិបញ្ញត្តិ (ឬសភាជាន់ខ្ពស់)។

### តើខ្ញុំបោះឆ្នោតជ្រើសរើសនរណា?

លោកអ្នកបោះឆ្នោត នៅក្នុងការបោះឆ្នោតប្រចាំរដ្ឋដើម្បីជ្រើសរើសបេក្ខជនម្នាក់ឲ្យធ្វើជាតំណាងលោកអ្នកនៅសភានីតិបញ្ញត្តិ និងបេក្ខជន៥នាក់ឲ្យធ្វើជាតំណាងលោកអ្នកនៅក្រុមប្រឹក្សានីតិបញ្ញត្តិ។ អ្នកតំណាងទាំងនេះធ្វើការសំរាប់អាណត្តិ៤ឆ្នាំ។

## ការបោះឆ្នោតប្រចាំសាលាក្រុង

ការបោះឆ្នោតសាលាក្រុងសំរាប់សង្កាត់រដ្ឋវិចតូរីយ៉ាចំនួន៧៩ដែលប្រព្រឹត្តទៅរៀងរាល់៤ឆ្នាំម្តង នៅថ្ងៃសៅរ៍ចុងក្រោយក្នុងខែវិច្ឆិកា។

សាលាក្រុងរបស់លោកអ្នក អាចជ្រើសរើសចាត់ចែងការបោះឆ្នោតតាមប៉ុស្តិ៍ ឬការបោះឆ្នោតដោយផ្ទាល់ខ្លួន។

### តើខ្ញុំបោះឆ្នោតជ្រើសរើសនរណា?

លោកអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតប្រចាំសាលាក្រុងដើម្បីជ្រើសរើសបេក្ខជន១នាក់ ឬបេក្ខជនច្រើននាក់សំរាប់មណ្ឌល ឬសង្កាត់របស់លោកអ្នក ដើម្បីឲ្យធ្វើជាតំណាងលោកអ្នកនៅសាលា

ក្រុងសំរាប់អាណត្តិ៤ឆ្នាំ។ នៅក្នុងទីក្រុងម៉ែលប៊ន លោកអ្នកក៏ត្រូវបោះឆ្នោតជ្រើសរើសផ្ទាល់សំរាប់ចៅហ្វាយក្រុង និងចៅហ្វាយក្រុងរងផងដែរ។

សង្កាត់ខ្លះនៅក្នុងរដ្ឋវិចតូរីយ៉ា មិនបានចែងចែកទេ (មណ្ឌលបោះឆ្នោតមួយធំ)។ កន្លែងដទៃទៀតត្រូវបានបែងចែកជាមណ្ឌល (មណ្ឌលបោះឆ្នោតមួយចំនួនតូចៗ)។ ចំនួនទីប្រឹក្សាដែលលោកអ្នកបោះឆ្នោតជ្រើសរើស និងទ្រង់ទ្រាយការបោះឆ្នោតរបស់សាលាក្រុងលោកអ្នកត្រូវបានសម្រេចដោយរដ្ឋមន្ត្រីទទួលបន្ទុកខាងរដ្ឋាភិបាលប្រចាំតំបន់។

## តើចង់ដឹងច្រើនថែមទៀតឬទេ?

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ហើយចង់ដឹងច្រើនថែមទៀតអំពីការចុះឈ្មោះ និងការបោះឆ្នោតសហព័ន្ធ រដ្ឋ និងរដ្ឋាភិបាលប្រចាំតំបន់ សូមទូរស័ព្ទលេខ **9209 0192**។

ឬទាក់ទងជាមួយយើងនៅ:

Victorian Electoral Commission
Level 8, 505 Little Collins Street
Melbourne Victoria 3000

ឬទូរស័ព្ទមកយើងលេខ 13 18 32

+61 3 9299 0520 (ពីក្រៅប្រទេសអូស្ត្រាលី)
9299 0570 ទូរស័ព្ទវាយជាអក្សរ (សំរាប់អស់អ្នកដែលមានការអន់ខ្សោយខាងការស្តាប់ឮ)

ប្រសិនបើលោកអ្នកចង់ជ្រើសរើសឈរឈ្មោះជាបេក្ខជនសំរាប់សភាតំណាងរាស្ត្រ ឬព្រឹទ្ធសភានៅក្នុងការបោះឆ្នោតសហព័ន្ធ សូមទូរស័ព្ទ AEC លេខ 13 23 26 ឬបើកមើលគេហទំព័រ www.aec.gov.au

បេក្ខជនដែលសង្ឃឹមថាបានទទួលការជ្រើសរើសសំរាប់សភាជាន់ខ្ពស់ និងសភាជាន់ទាប នៅក្នុងការបោះឆ្នោតប្រចាំរដ្ឋ ឬសំរាប់ការបោះឆ្នោតសាលាក្រុងក្នុងរដ្ឋវិចតូរីយ៉ា គួរទាក់ទងជាមួយ VEC។